DIETHELM TRAVEL

DIETHELM TRAVEL CAMBODIA
NO. 65, STREET 240, PO BOX 99,
PHNOM PENH, CAMBODIA
TEL : +855 23 219 151
FAX : +855 23 219 150
E-MAIL : DT_Cambodia@kh.diethelmtravel.com
www.diethelmtravel.com

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាយកក្រុមហ៊ុនទេសចរណ៍ឌៀថែមត្រាវែល**

***<u>សូមគោរពជូន</u>***

**លោកប្រធានសមាគម ទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)**

**កម្មវត្ថុ** : សំណើរសុំជួយធ្វើអន្តរាគមន៍អនុញ្ញាតិអោយរថយន្តចំនួន ៤ គ្រឿងរបស់ក្រុមហ៊ុនទេសចរណ៍ឌៀថែមត្រាវែល DIETHELM TRAVEL (CAMBODIA) LTD. ចូលមកទស្សនះកិច្ចនៅតាមរមណីយដ្ឋានទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ ដល់ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១០។

**យោង** : លិខិតជូនដំណឹងរបស់ក្រុមហ៊ុនដៃគូរនៅក្រៅប្រទេស GOANNA TRACKS ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១០។

សេចក្តីដូចបានជំរាបជូនតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនលោកប្រធានសមាគមមេត្តាជ្រាបថា: ក្រុមហ៊ុនទេសចរណ៍របស់ខ្ញុំបាទបានទទួលភ្ញៀវទេសចរណ៍០១ក្រុមមកទស្សនះកិច្ចនៅតាមបណ្តារមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ និង ធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដោយធ្វើដំណើរតាមរថយន្តចំនួន ៤គ្រឿង។ ដើម្បីបង្កលក្ខណៈងាយស្រួលជូនដល់ភ្ញៀវទេសចរណ៍តាមសំណូមពររបស់ភ្ញៀវ និង ស្របតាមគោលនយោបាយបើកចំហរជើងមេឃ ផ្លូវសមុទ្រ ផ្លូវទន្លេ និង តាមច្រកទ្វារព្រំដែនអន្តរជាតិនានារបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាផងនោះ ក្រុមហ៊ុនទេសចរណ៍ខ្ញុំបាទសុំការជួយអន្តរាគមន៍អនុញ្ញាតិអោយរថយន្តរបស់ភ្ញៀវទេសចរណ៍បានចូលបណ្តោះអាសន្នមកព្រះរាជាណាចក្រកម្ពុជាតាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយ ប៉ែត ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ២០១០ ហើយត្រលប់ទៅវិញនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១០ តាមច្រកទ្វារព្រំដែនអន្តរជាតិ ដុងក្រឡ (ត្រពាំងក្រៀល) ខេត្ត ស្ទឹង ត្រែង។

អាស្រ័យហេតុនេះ សូមលោកប្រធានសមាគមមេត្តាពិនិត្យ និង អនុញ្ញាតិផ្តល់ការជួយអន្តរាគមន៍ជាមួយស្ថាប័នពាក់ព័ន្ធដោយក្តីអនុគ្រោះ។

សូមលោកប្រធានមេត្តាទទួលយកនូវសេចក្តីគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំបាទ។

**សូមជូនភ្ជាប់:**

- លិខិតរបស់ក្រុមហ៊ុន KYM BOLTON
- បញ្ជីរឈ្មោះអ្នកបើកបរនិងលិខិតឆ្លងដែន
- បញ្ជីរឈ្មោះរថយន្ត

ធ្វើនៅភ្នំពេញ ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ២០១០

ហត្ថលេខា

DIETHELM TRAVEL CAMBODIA.LTD

ប្រធានក្រុមហ៊ុនទេសចរណ៍ឌៀថែមត្រាវែល

ព្យែរ យ៉ាំងឡោ